ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ ០២៣/០១ អបស/មព

# សេចក្តីណែនាំ

## ស្តីពីការចេញវិញ្ញាបនប័ត្រពេទ្យ

ដើម្បីបំពេញបែបបទរដ្ឋបាលក្នុងការចេញវិញ្ញាបនប័ត្រពេទ្យ សម្រាប់ប្រើប្រាស់បំពេញសំណុំលិខិតផ្នែកតុលាការដូចជា វិញ្ញាបនប័ត្របញ្ជាក់ស្លាកស្នាមរបួស ពិការ កោសល្យវិច័យ ។ល។ ក្រសួងសុខាភិបាលសូមធ្វើការណែនាំដូចខាងក្រោមនេះ៖

**១-អំពីសមត្ថកិច្ច និងការទទួលខុសត្រូវក្នុងចេញវិញ្ញាបនប័ត្រពេទ្យ (កោសល្យវិច័យ) អង្គភាពរដ្ឋនិងឯកជនដែលមានសិទ្ធិទទួលពិនិត្យព្យាបាល និងចេញវិញ្ញាបនប័ត្រពេទ្យ ( កោសល្យវិច័យ) គឺ៖**

ក-មន្ទីរពេទ្យជាតិដែលមានមន្ទីរពេទ្យកាល់ម៉េត មន្ទីរពេទ្យព្រះបាទនរោត្តមសីហនុ មន្ទីរពេទ្យព្រះកុសុមៈមន្ទីរពេទ្យព្រះអង្គឌួង មន្ទីរពេទ្យកុមារជាតិ មន្ទីរពេទ្យគន្ធបុប្ផា មជ្ឈមណ្ឌលគាំពារមាតា និងទារក និងវិជ្ជាស្ថានកំចាត់រោគរបេង ។

ខ-មន្ទីរពេទ្យបង្អែករាជធានីភ្នំពេញ និងខេត្ត-ក្រុង

គ-សេវាឯកជនដែលមានច្បាប់ត្រឹមត្រូវ

វិញ្ញាបនប័ត្រពេទ្យ(កោសល្យវិច័យ) ទាំងនេះអាចប្រើប្រាស់បានជាផ្លូវការលុះត្រាតែមានចុះហត្ថលេខា និងឈ្មោះរបស់គ្រូពេទ្យដែលបានពិនិត្យព្យាបាល ដោយមានការឯកភាពពីប្រធាន-អនុប្រធានមន្ទីរពេទ្យចំពោះមន្ទីរពេទ្យជាតិ និងមន្ទីរពេទ្យបង្អែក និងដោយមានការឯកភាពពីប្រធានសេវាចំពោះសេវាឯកជ ។

**២-ប្រតិវិញ្ញាបនប័ត្រពេទ្យ (ប្រតិកោសល្យវិច័យ)**

ក្នុងករណីដែលមានភាពមិនប្រក្រតីលើវិញ្ញាបនប័ត្រពេទ្យ កោសល្យវិច័យ មានការតវ៉ាផ្សេងៗដែលអាចកើតមានជាយថាហេតុ ស្ថាប័នពាក់ព័ន្ធអាចស្នើសុំប្រតិវិញ្ញាបនប័ត្រពេទ្យ (ប្រតិកោសល្យវិច័យ) ដោយឆ្លងកាត់ក្រសួងសុខាភិបាល ។

**៣-អំពីបែបបទនៃការស្នើសុំវិញ្ញាបនប័ត្រពេទ្យ(កោសល្យវិច័យ)**

ការចេញវិញ្ញាបនប័ត្របញ្ជាក់ស្លាកស្នាមរបួសពិការ (កោសល្យវិច័យ) អាចធ្វើទៅបានលុះត្រាតែមានការស្នើសុំពីក្រសួងយុត្តិធម៌ តុលាការខេត្ត-ក្រុង អធិការដ្ឋាននគរបាលខេត្ត-ក្រុង ដែលពាក់ព័ន្ធក្នុងការដោះស្រាយរឿងវិវាទ និងសាមីខ្លួនដែលពាក់ព័ន្ធក្នុងការបំពេញសំណុំលិខិតពាក្យបណ្តឹងនានា លិខិតស្នើសុំចេញវិញ្ញាបនប័ត្រខាងលើត្រូវធ្វើផ្ទាល់ទៅមន្ទីរពេទ្យ ឬ ទៅសេវាឯកជនដូចមានចែងក្នុងចំណុច ក-ខ-គ ស្តីពីសមត្ថកិច្ច និងការទទួលខុសត្រូវក្នុងការចេញវិញ្ញាបនប័ត្រពេទ្យ (កោសល្យវិច័យ) ខាងលើ ។ សេចក្តីណែនាំនេះត្រូវអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០១

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

វេជ្ជ:. **ហុង ស៊ុនហួត**

កន្លែងទទួល:

- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ
- -សាលាខេត្ត-ក្រុង ដើម្បីជូនជ្រាបជាព័ត៌មាន
- -ខុទ្ទកាល័យក្រសួងសុខាភិបាល
- -អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល
- -អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- -អគ្គាធិការដ្ឋាន
- -មន្ទីរពេទ្យជាតិ
- -មន្ទីរសុខាភិបាលខេត្ត-ក្រុង
- -ដើម្បីអនុវត្ត ឯកសារ-កាលប្បវត្តិ